00173230

C11/53

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គបុរេជំនុំជម្រះ

PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០១)

**អង្គបុរេជំនុំជម្រះ**

**ចំពោះមុខ:** ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ធុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**ក្រឡាបញ្ជីសវនាការ** កែវ ទ៉ាន្នី
Dirk Jan LAMAN

**កាលបរិច្ឆេទ:** ២០ មីនា ២០០៨

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 03 / 2008
ម៉ោង (Time/Heure): 14:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier:

**សាលដីកាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ នួន ជា**

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**

នួន ជា

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោក ហុង គឹមសួន
លោក ឡោ ជុនធី
លោក នី ចាន់ឌី

**សហមេធាវីការពារក្តី**

លោក សុន អរុណ
Michiel PESTMAN
Victor KOPPE

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 24 / 03 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier:

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C.

00173231

C11/53

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០១)

# I- ប្រវត្តិ

## ក- ស្ថានភាពនៃការដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

១- នៅថ្ងៃទី ៧ និងទី ៨ ខែ កុម្ភៈ ឆ្នាំ ២០០៨ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានបើកសវនាការបណ្តឹងឧទ្ធរណ៍ដែលសហមេធាវីរបស់ជនត្រូវចោទ នួន ជា បានប្តឹងជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ("បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន")។

២- នាពេលសវនាការ មានដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួននាក់ចូលរួមនៅក្នុងនីតិវិធីព្រហ្មទណ្ឌក្នុងសំណុំរឿងលេខ ០០២/១៩-០៩-០៧-អវតក/កសចស។ នៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៧ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងជាផ្លូវការដល់ដើមបណ្តឹងរដ្ឋប្បវេណី[1]។ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតក៏បានដាក់ផងដែរនូវអនុស្សរណៈអន្តរការិយាល័យ អំពីពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីរ មកអង្គបុរេជំនុំជម្រះជាបន្តបន្ទាប់ កាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៧[2] និងថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៧[3]។ ឯកសារអនុស្សរណៈនោះបានជម្រាបជូនអង្គបុរេជំនុំជម្រះថា ពាក្យបណ្តឹងទាំង

---

[1] ស្ថានភាពនៃការដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ នៃរឿងក្តីជនត្រូវចោទ នួន ជា (សំណុំរឿង:០០២/១៩-០៩-២០០៧-អវតក/កសចស D២២/១/១)។ ស្ថានភាពនៃការដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ នៃរឿងក្តីជនត្រូវចោទ នួន ជា (សំណុំរឿង: ០០២/១៩-០៩-២០០៧-អវតក/កសចស D២២/៦/២)។ ស្ថានភាពនៃការដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ នៃរឿងក្តីជនត្រូវចោទ នួន ជា (សំណុំរឿង: ០០២/១៩-០៩-២០០៧-អវតក/កសចស D២២/៧/២)។ ស្ថានភាពនៃការដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ នៃរឿងក្តីជនត្រូវចោទ នួន ជា (សំណុំរឿង: ០០២/១៩-០៩-២០០៧-អវតក/កសចស D២២/២/២)។

[2] អនុស្សរណៈអន្តរការិយាល័យស្តីពីស្ថានភាពនៃការដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេង ចំនួនពីររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧ នៃរឿងក្តីជនត្រូវចោទ នួន ជា (សំណុំរឿង: ០០២/១៩-០៩-២០០៧-អវតក/កសចស A៧០)។

[3] អនុស្សរណៈអន្តរការិយាល័យស្តីពីស្ថានភាពនៃការដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ នៃរឿងក្តីជនត្រូវចោទ នួន ជា (សំណុំរឿង: ០០២/១៩-០៩ [illegible]

នោះត្រូវបានជូនដំណឹងដល់គូភាគីដទៃទៀត និងជនត្រូវចោទរួចរាល់ហើយ និងអ្នកដាក់ពាក្យប្តឹងអាចចាត់ទុកថាជាដើមបណ្តឹងរដ្ឋប្បវេណីបានសម្រាប់គ្រប់គោលបំណងទាំងអស់ ដែលពាក់ព័ន្ធនឹងសំណុំរឿងលេខ 00២/១៩-0៩-0៧-អវតក/កសចស។

៣- ដោយឈរលើមូលដ្ឋានអនុស្សារណៈចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២00៧ នៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២00៧ អង្គបុរេជំនុំជម្រះបានជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន[4]។ នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២00៧ អង្គបុរេជំនុំជម្រះបានកំណត់ថ្ងៃបើកសវនាការលើបណ្តឹងឧទ្ធរណ៍នោះគឺនៅថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២00៨[5]។ នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២00៨ ប្រធានអង្គបុរេជំនុំជម្រះបានជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនថា ដោយយោងតាមវិធាន៧៧(៤) នៃវិធានផ្ទៃក្នុង (“វិធាន”) មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចពិនិត្យមើលសំណុំរឿងរហូតដល់ថ្ងៃបើកសវនាការ ហើយមេធាវីត្រូវដាក់សារណារបស់ខ្លួនដូចមានចែងនៅក្នុងសេចក្តីណែនាំអនុវត្ត អវតក/0១/២00៧/Rev.១ ស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក[6]។ នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២00៨ អង្គភាពជនរងគ្រោះបានជូនដំណឹងមកអង្គបុរេជំនុំជម្រះអំពីការតែងតាំងមេធាវីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងបួន និងអំពីគោលបំណងរបស់ពួកគេក្នុងការចូលរួមនៅក្នុងសវនាការផងដែរ។ នៅថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២00៨ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីសម្រេចទទួលស្គាល់មេធាវី ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២00៨[7] ដោយទទួលស្គាល់លោក **ហុង គីមសួន** លោក **ឡោ ជុនធី** និង លោក **នី ចាន់ឌី** ជាមេធាវីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងបួននាក់នេះ។

---

២00៧-អវតក/កសចស A៩៣) ។

[4] ការដាក់បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ នួន ជា ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២00៧ នៃរឿងក្តីជនត្រូវចោទ នួន ជា(សំណុំរឿង: 00២/១៩-0៩-២00៧-អវតក/កសចស(អបជ0១) C១១/៩)។

[5] ដីកាកំណត់ថ្ងៃបើកសវនាការ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២00៧ នៃរឿងក្តីជនត្រូវចោទ នួន ជា (សំណុំរឿង: 00២/១៩-0៩-២00៧-អវតក/កសចស(អបជ0១) C១១/១៤)។

[6] ស្ថានភាពនៃការដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២00៨ នៃរឿងក្តីជនត្រូវចោទ នួន ជា (សំណុំរឿង: 00២/១៩-0៩-២00៧-អវតក/កសចស C១១/១៧)។

[7] សេចក្តីសម្រេចទទួលស្គាល់មេធាវី ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២00៨ នៃរឿងក្តីជនត្រូវចោទ នួន ជា (សំណុំរឿង: 00២/១៩-0៩-២00៧-អវតក/កសចស D២២/៧/៥)។ សេចក្តីសម្រេចទទួលស្គាល់មេធាវី ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២00៨ នៃរឿងក្តីជនត្រូវ សាលដីកាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00173233



៤- មុនពេលកំណត់ថ្ងៃបើកសវនាការនៅថ្ងៃទី៤ ខែ កុម្ភៈ ឆ្នាំ ២០០៨ អង្គបុរេជំនុំជម្រះបានបញ្ជូនឯកសារមួយ ដែលមានចំណងជើងថា "នីតិវិធីជំនុំជម្រះរឿងព្រហ្មទណ្ឌ" ទៅអោយភាគី ដោយបង្ហាញពីនីតិវិធីដែលត្រូវអនុវត្តនាពេលសវនាការ ព្រមទាំងបង្ហាញពីចំណុចដែលប្រធានអង្គបុរេជំនុំជម្រះនឹងអញ្ជើញមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីអោយធ្វើសេចក្តីសន្និដ្ឋាន ប្រសិនបើអាចធ្វើបាន។ នាពេលសវនាការ មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអញ្ជើញឲ្យបញ្ចេញយោបល់ ចំពោះការស្នើសុំពន្យារពេលសវនាការរបស់សហមេធាវីជនត្រូវចោទ។ មុនពេលកំណត់ឡើងវិញអំពីកាលបរិច្ឆេទបើកសវនាការនៅថ្ងៃទី ៧ ខែ កុម្ភៈ ឯកសារកែប្រែថ្មីនៃ "នីតិវិធីជម្រះរឿងព្រហ្មទណ្ឌ" ត្រូវបានបញ្ជូនទៅអោយគូភាគី ដោយមានបញ្ជាក់ពីឈ្មោះមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងបញ្ជាក់ផងដែរថា ពួកគេម្នាក់ៗត្រូវបានអនុញ្ញាតអោយធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនបានតែ ៣០ នាទី ប៉ុណ្ណោះ។

## ខ- ឧត្តិករណ៍របស់ភាគីក្នុងសវនាការ នៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០០៨

៥- នៅក្នុងសវនាការ សហមេធាវីជាតិបានលើកឡើងថា យោងតាមវិធាន ២៣ នៃវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតអោយចូលរួមតែក្នុងសវនាការលើអង្គសេចក្តីប៉ុណ្ណោះ មិនមែននៅក្នុងនីតិវិធីមុនអង្គសេចក្តីនោះទេ។ បន្ទាប់មកទៀត មេធាវីរូបនេះបានលើកឡើងពីចំណុចជុំវិញផលលំបាកនៃការមានដើមបណ្តឹងដល់ទៅពីរ គឺមានទាំងជនត្រូវចោទ និងជនរងគ្រោះ នៅក្នុងនីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន។ សហមេធាវីអន្តរជាតិបានលើកឡើងថា វិធាន ២៣ មិនមាននិយាយអ្វីទាល់តែសោះ ចំពោះវិសាលភាពនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែដោយសារសញ្ញាណនៃការចូលរួមនៅក្នុងវិធាន ២៣(១)(ក) សន្មត់ទុកជាមុននូវផលប្រយោជន៍ស្តែងចេញពីលទ្ធផលនៃដំណើរការនីតិវិធីនោះ ដូច្នេះគួរយកវិធីសាស្ត្រតឹងរ៉ឹងមួយមកអនុវត្ត។ សហមេធាវីរូបនេះបាន

---

ចោទ នួន ជា (សំណុំរឿង:០០២/១៩-០៩-២០០៧-អវតក/កសចស D២២/២/៥)។ លិខិតប្រគល់សិទ្ធិដល់មេធាវីតំណាងដោយអាណត្តិ ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០៨ នៃរឿងក្តីជនត្រូវចោទ នួន ជា (សំណុំរឿង: ០០២/១៩-០៩-២០០៧-អវតក/កសចស D២២/២/៣)។

លើកយកសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិនៅក្នុងរឿងក្តី *Lubanga* ដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួន។[8] សហមេធាវីរូបនេះបានលើកឡើងទៀតថា អង្គជំនុំជម្រះត្រូវតែធានាថា រាល់ទស្សនៈ និងកង្វល់នានារបស់ជនរងគ្រោះត្រូវតែបង្ហាញក្នុងវិធីណាមួយដែលមិនប៉ះពាល់ដល់ប្រយោជន៍ ឬផ្ទុយទៅនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីមួយដោយយុត្តិធម៌។ មានការកត់សម្គាល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សារណា ឬធ្វើការលើកឡើងអំពីផលប្រយោជន៍របស់ខ្លួនអោយគេបានដឹងទេ។

៦- សហព្រះរាជអាជ្ញាជាតិបានឆ្លើយតបទៅវិញថា វិធានផ្ទៃក្នុងមិនបានបញ្ជាក់ច្បាស់ទេថា ពេលណាដែលដើមបណ្តឹងរដ្ឋប្បវេណីគួរចូលរួមនៅក្នុងដំណើរការនីតិវិធី ហើយបានស្នើសុំអោយតុលាការធ្វើការសម្រេចចំពោះបញ្ហានេះ។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា វិធាន ២៣ មិនបានកំណត់អត្ថន័យនៃពាក្យ "ដំណើរការនីតិវិធី"ទេ ហើយសហព្រះរាជអាជ្ញាក៏បានលើកឡើងពីការវិវត្តន៍ផ្លាស់ប្តូរនៃទម្លាប់អនុវត្តក្នុងរឿងក្តីព្រហ្មទណ្ឌអន្តរជាតិ ដែលត្រូវបញ្ចូលឲ្យមានការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលស៊ើបអង្កេត។ សហព្រះរាជអាជ្ញាបានបន្តលើកឡើងថា លទ្ធផលនៃរឿងក្តី *Lubanga* គឺថាជនរងគ្រោះមួយក្រុម ត្រូវបានអនុញ្ញាតអោយចូលរួមក្នុងរឿងបណ្តឹងឧទ្ធរណ៍នៃការឃុំខ្លួនបណ្តោះអាសន្ន ហើយអង្គបុរេជំនុំជម្រះបានអនុវត្តក្នុងវង្វង់នៃវិធាន ២៣។

៧- មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា តាមវិធាន ២៣ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមក្នុងដំណើរការនីតិវិធី តាំងពីពេលចាប់ផ្តើមនីតិវិធីចោទប្រកាន់ ហើយដើមបណ្តឹងរដ្ឋប្បវេណីមានតួនាទីជាអ្នកបង្ហាញអោយតុលាការបានដឹងអំពីផលប៉ះពាល់បែបណាខ្លះ ដែលអាចកើតមានដល់សង្គម ប្រសិនបើជនត្រូវចោទត្រូវបានដោះលែង។

## គ- សេចក្តីសម្រេចបន្តសវនាការដោយរក្សាសិទ្ធិគ្រប់យ៉ាង

---

[8] រឿងក្តីព្រះរាជអាជ្ញា ទល់នឹង Thomas Lubanga *Dyilo* សំណុំរឿងលេខ: ICC-01/04-01/06 "*សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ជំទាស់នឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទី១*" ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០០៧

៨- អង្គបុរេជំនុំជម្រះបានពិភាក្សា និងស្តាប់នូវសេចក្តីសន្និដ្ឋានជាបន្តបន្ទាប់ ដែលបង្ហាញអោយឃើញពីផលប្រយោជន៍រួមក្នុងការបន្តសវនាការទៅមុខទៀត។ សវនាការបានបន្តដោយឈរលើមូលដ្ឋានដែលថា ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ពួកគេនឹងដាក់សារណាលាយលក្ខណ៍អក្សរ ទៅអោយសហមេធាវីការពារក្តីជាមុន ហើយដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ពួកគេនឹងទទួលបានការអនុញ្ញាតអោយធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន។បន្ទាប់ពីការសម្រេចរបស់អង្គបុរេជំនុំជម្រះអំពីបញ្ហាការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី និង/ឬ សារណារបស់មេធាវីរបស់ពួកគេនឹងត្រូវទទួលយក ឬច្រានចោល តាមការសមស្របមុននឹងមានការសម្រេចពីបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន។

៩- នៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៨ អង្គបុរេជំនុំជម្រះបានចេញសេចក្តីជូនដំណឹងអោយក្រុមមេធាវីការពារក្តីទាំងអស់ ដែលពាក់ព័ន្ធនឹងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន អោយសហព្រះរាជអាជ្ញា ព្រមទាំងដើមបណ្តឹងរដ្ឋប្បវេណី ដាក់សារណាលើបញ្ហាដែលដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនៅក្នុងសវនាការ និងអញ្ជើញអ្នកមិនមែនជាភាគីនៃរឿងក្តីអោយដាក់នូវសារណារបស់ខ្លួនត្រឹមថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០៨។[9] អង្គបុរេជំនុំជម្រះបានសិក្សាលើ "សារណាណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តីដែលបានលើកឡើងពីបញ្ហាតុល្យភាពរវាងសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ និងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងបរិបទនៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក"។ ភាគីទាំងអស់ត្រូវបានអនុញ្ញាតអោយដាក់នូវសារណាតបរបស់ខ្លួន ត្រឹមថ្ងៃទី០៦ ខែ មីនា ឆ្នាំ ២០០៨។

**ឃ- សំណើពីសហមេធាវីរបស់ជនត្រូវចោទ**

១០- នៅក្នុងសារណារបស់ខ្លួន សហមេធាវីរបស់ជនត្រូវចោទទាំងអស់បានស្នើសុំទៅអង្គបុរេជំនុំជម្រះឱ្យៈ (i) ដកសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី ចេញពីសំណុំឯកសារបណ្តឹងឧទ្ធរណ៍របស់ **នួន ជា** និង (ii)

[9] សេចក្តីជូនដំណឹងស្តីពីការដាក់សារណាលើបញ្ហាការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងការអញ្ជើញអ្នកមិនមែនជាភាគីនៃរឿងក្តី ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៨ នៃរឿងក្តីជនត្រូវចោទ នួន ជា (សំណុំរឿងៈ ០០២/១៨-០៩-២០០៧-អវតក/កសចស(អបជ០១) C១១/៣៦)។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ច្រានចោលជាមុននូវការចូលរួមពេលក្រោយទៀតរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការនីតិវិធីទាក់ទង នឹងការឃុំខ្លួនបណ្តោះអាសន្ន។

## II- សារណាជាលាយលក្ខណ៍របស់គូភាគី

១១- សហមេធាវីការពារក្តីនៅក្នុងរឿងក្តីទាំងបួន ដែលរងការប៉ះពាល់ពីសេចក្តីសម្រេចបច្ចុប្បន្ន បានដាក់សារណា[10] ដោយលើកឡើងនូវទឡ្ហីករណ៍ដូចខាងក្រោមៈ

(i) យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា សំណងជម្ងឺចិត្តគឺជាគោលបំណងតែមួយគត់របស់បណ្តឹងរដ្ឋប្បវេណី បន្ទាប់ពីការសម្រេចលើពិរុទ្ធភាព។ លើសពីនេះ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចប្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឬដីកាបង្គាប់ដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានឡើយ ហើយទាំងចៅក្រមស៊ើបអង្កេត និងសាលាដំបូង មិនត្រូវបានតម្រូវអោយស្តាប់សេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី មុននឹងចេញដីកាបង្គាប់ឱ្យដោះលែង ឬបន្តឃុំខ្លួនជនត្រូវចោទណាម្នាក់នោះដែរ។

(ii) វិធានផ្ទៃក្នុងក៏មានលក្ខណៈស្របគ្នានឹងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជាដែរ លើបញ្ហាជំហរស្របគ្នារបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនអនុញ្ញាតអោយភាគីដើមបណ្តឹងរដ្ឋប្បវេណីប្តឹងឧទ្ធរណ៍ជំទាស់នឹងសេចក្តីសម្រេចក្នុងរឿងឃុំខ្លួនបណ្តោះអាសន្នឡើយ។

(iii) នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ជនរងគ្រោះត្រូវសុំការអនុញ្ញាតដើម្បីចូលរួមក្នុងរឿងបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន ដែលពួកគេមានបន្ទុកផ្ទាល់ក្នុងការបង្ហាញថាតើផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេត្រូវប៉ះពាល់យ៉ាងដូចម្តេច ហើយបង្ហាញពីភាពសមស្របនៃការចូលរួមរបស់ពួកគេ និងភាពគ្មានការប៉ះពាល់ទៅលើផលប្រយោជន៍ដល់មេធាវីការពារក្តី។ ទោះជាបន្ទុកនេះអាចជាហេតុផលអាចទទួលយកបានក៏ដោយ ក៏អង្គជំនុំជម្រះអាចបដិសេធការចូលរួមរបស់ពួកគេបានដែរ ដោយសារការចូលរួមនេះមិនមានអត្ថប្រយោជន៍។

---

[10] សារណារួមគ្នាស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ នៃរឿងក្តីជនត្រូវចោទ នួន ជា (សំណុំរឿង:០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០១) C១១/៤៥)



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00173237

C11/53



(iv) អង្គបុរេជំនុំជម្រះគ្មានយុត្តាធិការក្នុងការអនុញ្ញាតអោយដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងរឿងបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្នទេ ដោយសារតែពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេ មិនត្រូវបានសហចៅក្រមស៊ើបអង្កេតពិនិត្យមើលឡើងវិញ និងទទួលស្គាល់ជាផ្លូវការឡើយ។

(v) ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងរឿងបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនបណ្តោះអាសន្នត្រូវបានហាមឃាត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា និងវិធានផ្ទៃក្នុង ពេលដែលយកវាមកអានជាមួយគ្នា និងអនុវត្តនៅចំពោះមុខតុលាការកម្ពុជា។

(vi) ជំនួសមកវិញ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចចូលរួមនៅក្នុងដំណើរការនីតិវិធី ដែលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេមិនត្រូវបានប៉ះពាល់ និងកង្វល់ជាទូទៅផ្សេងៗទៀតដែលត្រូវបានបញ្ជាក់ការពារដោយអយ្យការ។

(vii) ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី មានលក្ខណៈផ្ទុយពីសិទ្ធិរបស់ជនត្រូវចោទ ព្រោះការចូលរួមនេះអាចធ្វើអោយមានការពន្យារដំណើរការនីតិវិធី និងដាក់បន្ទុកមិនយុត្តិធម៌មកលើមេធាវីការពារក្តីក្នុងការឆ្លើយតបទៅនឹងអ្នកជំទាស់ដ៏ច្រើន ហើយវាមានហានិភ័យក្នុងការដាក់ឯកសារភស្តុតាងជាច្រើនដែលមិនពាក់ព័ន្ធ និងប៉ះពាល់យ៉ាងខ្លាំងទៅក្នុងដំណើរការនីតិវិធី។

១២- សហព្រះរាជអាជ្ញា[11]លើកឡើងដូចខាងក្រោមថា:

(i) វិធាន ២៣ ចងក្រងជាច្បាប់ស្តីពីបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះ ហើយគោលបំណងរបស់បណ្តឹងនេះ គឺដើម្បីចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ដោយគាំទ្រការចោទប្រកាន់ និងអនុញ្ញាតអោយជនរងគ្រោះទាមទារសំណង។ ពាក្យថា "ដំណើរការនីតិវិធីព្រហ្មទណ្ឌ"នេះត្រូវបានប្រើដោយមិនមានកម្រិតវិសាលភាព និងគួរបកស្រាយដោយសំដៅទៅលើគ្រប់ដំ

---

[11]សារណារបស់សហព្រះរាជអាជ្ញាស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ នៃរឿងក្តីជនត្រូវចោទ នួន ជា (សំណុំរឿង: ០០២/១៩-០៩-២០០៧-អវតក/ កសចស (អបជ០១) C១១/៥៤)។

ណាក់កាលនៃដំណើរការនីតិវិធី។ វិធានផ្ទៃក្នុងរំពឹងថា ការចូលរួមអាចត្រូវបានធ្វើនិយ័តកម្ម តាមរយៈការស្នើសុំអោយដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនអោយមានមេធាវីរួមគ្នា។

(ii) ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក៏អនុញ្ញាតអោយជនរងគ្រោះតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយអនុញ្ញាតអោយចូលរួមនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីព្រហ្មទណ្ឌ ទោះបីជាពុំមាននិយាយពីការកម្រិតនៃការចូលរួមនៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍ជំទាស់ការឃុំខ្លួនបណ្តោះអាសន្នក៏ដោយ។

(iii) យុត្តាធិការផ្សេងៗជាច្រើនទៀត ដូចជា នៅប្រទេសបារាំង និង អេស្ប៉ាញ បានអនុញ្ញាតអោយជនរងគ្រោះចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ក្នុងកម្រិតខុសៗគ្នា។

(iv) នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ជនរងគ្រោះបានចូលរួមនៅក្នុងដំណើរការនីតិវិធីឃុំខ្លួនបណ្តោះអាសន្ន ហើយនៅក្នុងរឿងក្តី *Lubanga* អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានអនុញ្ញាតអោយជនរងគ្រោះ ចូលរួមនៅក្នុងដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការដោះលែងបណ្តោះអាសន្ន បន្ទាប់ពីបានតម្រូវអោយជនរងគ្រោះផ្តល់សេចក្តីថ្លែងការណ៍ពន្យល់ពីផលប៉ះពាល់ផលប្រយោជន៍របស់ខ្លួនរួចមក។

(v) ឯកសាររបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ គាំទ្រជាមធ្យោបាយយ៉ាងទូលំទូលាយដល់សិទ្ធិក្នុងការចូលរួមរបស់ជនរងគ្រោះ។

(vi) លិខិត និងស្មារតីនៃឯកសារជាមូលដ្ឋានរបស់ អ.វ.ត.ក នាំឱ្យមានការសន្និដ្ឋានបានថា ដើមបណ្តឹងរដ្ឋប្បវេណីគឺជាភាគីនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធី រួមទាំងដំណើរការនីតិវិធីលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្នផងដែរ។ បើទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីមិនចូលរួមក្នុងសវនាការតទល់គ្នា និងមិនមានសិទ្ធិប្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នក៏ដោយ ក៏ដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមក្នុងសវនាការបណ្តឹងឧទ្ធរណ៍ ដើម្បីគាំទ្រការចោទប្រកាន់ដែរ។ ការបកស្រាយណាមួយផ្ទុយពីនេះ គឺជាការរិតត្បិតសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានឋានៈជាភាគី ក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ពីព្រោះផលប្រយោជន៍របស់ដើមរដ្ឋប្បវេណីក្នុងដំណើការក្តីមិនត្រូវបានការពារតាមនីតិវិធីច្បាប់។

(vii) ការទទួលស្គាល់ជនរងគ្រោះជាភាគី គឺផ្អែកលើការពិចារណាលើគោលនយោបាយ និងនីតិវិធី



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

ច្បាប់។ ជនរងគ្រោះអាចបង្ហាញប្រាប់តុលាការពីបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន ដោយផ្អែកលើចំណេះដឹងផ្ទាល់របស់ពួកគេ។

(viii) អង្គបុរេជំនុំជម្រះគួរថ្លឹងថ្លែងរវាងសិទ្ធិរបស់ជនរងគ្រោះដែលមានចំនួនច្រើន ក្នុងការចូលរួមយ៉ាងមានប្រយោជន៍ក្នុងដំណើរការនីតិវិធី និងសិទ្ធិក្នុងការទទួលបានសវនការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័សរបស់ជនត្រូវចោទ។

(ix) ដូច្នេះ សហព្រះរាជអាជ្ញាសូមស្នើអោយមានសេចក្តីណែនាំប្រាំបីចំណុចចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលសវនាការបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះសន្ន។

១៣- ដើមបណ្តឹងរដ្ឋប្បវេណីលើកទឡ្ហីករណ៍ដូចខាងក្រោម:

(i) នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា និងប្រព័ន្ធច្បាប់ **ស៊ីវិល ឡ** (Civil Law) ដទៃទៀត ជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីទាមទារសំណង ហើយមានសិទ្ធិដូចភាគីដទៃទៀតដែរ។ ទឡ្ហីករណ៍នេះយោងទៅលើមាត្រា ២៥៩ និងមាត្រា ២៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងឧទាហរណ៍រឿងក្តីជាច្រើននៅប្រទេសកម្ពុជា ដែលដើមបណ្តឹងរដ្ឋប្បវេណីមានវត្តមានក្នុងនីតិវិធីបណ្តឹងឧទ្ធរណ៍អំពីការឃុំខ្លួនបណ្តោះអាសន្ន ឬការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

(ii) ច្បាប់កម្ពុជាពិតជាអនុញ្ញាតឱ្យមានវត្តមានដើមបណ្តឹងរដ្ឋប្បវេណីនៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី ហើយដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការកត់សម្គាល់ផ្សេងៗបានក្នុងអំឡុងពេលសវនាការ។ ការអនុវត្តបែបនេះមិនផ្ទុយនឹងបទដ្ឋានអន្តរជាតិទេ។

(iii) វត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនរំលោភទៅលើសិទ្ធិទទួលបានការកាត់សេចក្តីដោយយុត្តិធម៌របស់ជនត្រូវចោទនោះទេ។ការរំលោភសិទ្ធិនេះអាចកើតមានឡើង តែក្នុងករណីដែលមានការរំលោភទៅលើសិទ្ធិជាក់ស្តែងណាមួយប៉ុណ្ណោះ ដូចជាសិទ្ធិមានមេធាវីការពារក្តីជាដើម។

(iv) ផ្ទុយពីការអនុវត្តនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ក៏ដូចជាច្បាប់



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ស្ដីពីការបង្កើតអ.វ.ត.ក និងវិធានផ្ទៃក្នុង ពុំបានតម្រូវឱ្យជនរងគ្រោះបង្ហាញថា ប្រយោជន៍ផ្ទាល់ខ្លួនទទួលការប៉ះពាល់នោះទេ។ ជនរងគ្រោះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិមិនទទួលបានឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីទេហើយការអនុវត្តនៅតុលាការព្រហ្មទណ្ឌអន្តរជាតិមិនចងកាតព្វកិច្ចឱ្យអ.វ.ត.ក ត្រូវតែអនុវត្តតាមនោះដែរ។

(v) ក្នុងច្បាប់កម្ពុជា ពុំមានការចងកាតព្វកិច្ចដែលត្រូវតែដាក់សារណានោះទេ ហើយការខកខានមិនបានដាក់សារណានេះមិនអាចចាត់ទុកថាជាការបោះបង់សិទ្ធិក្នុងការធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់នោះដែរ។

(vi) វិធាន ២៣(១)(ក) មានន័យថា ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវមានសិទ្ធិដូចគ្នានឹងមេធាវីការពារក្ដី និងអយ្យការដែរ។ អនុលោមតាមវិធានផ្ទៃក្នុងនេះ ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមក្នុងសវនាការបណ្ដឹងឧទ្ធរណ៍ ដោយមិនចាំបាច់សុំការអនុញ្ញាតជាមុនឡើយ។

## III- សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្ដី

១៤- អង្គបុរេជំនុំជម្រះសូមសម្ដែងការអរគុណចំពោះសារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្ដី ដែលអង្គបុរេជំនុំជម្រះបានទទួលពី:

- Anne Heindel ទីប្រឹក្សាច្បាប់នៃមជ្ឈមណ្ឌលឯកសារកម្ពុជា[12]
- Christoph Safferling សាស្ត្រាចារ្យនៃសកលវិទ្យាល័យហ្វីលីព នៅ Marburg[13]
- វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ[14]

---

[12] សារណារបស់អ្នកមិនមែនជាភាគី ឈ្មោះ Anne Heindel ទីប្រឹក្សាច្បាប់នៃមជ្ឈមណ្ឌលឯកសារកម្ពុជា "*ស្ដីពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន*" ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ នៃរឿងក្ដីជនត្រូវចោទ នួន ជា (សំណុំរឿង:០០២/១៩-០៩-២០០៧-អវតក/ កសចស(អបជ០១) C១១/៣៨)។

[13] សារណារបស់អ្នកមិនមែនជាភាគី បណ្ឌិត Christoph Safferling សាស្ត្រាចារ្យនៃសកលវិទ្យាល័យហ្វីលីព នៅ Marburg "*សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្ដីលើសំណុំរឿងព្រហ្មទណ្ឌលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០១)*" ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ នៃរឿងក្ដី ជនត្រូវចោទ នួន ជា (សំណុំរឿង: ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០១) C១១/៣៩)។

[14] សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្ដីគឺ វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ "*សារណារបស់អ្នកមិនមែនជាភាគីនៃរឿង*" សាលដីកាអំពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

C11/53



- សមាគមអ្នកច្បាប់ដើម្បីការអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)[15]
- អង្គការ Redress Trust, អង្គការសហព័ន្ធសិទ្ធិមនុស្សអន្តរជាតិ(FIDH) និងអង្គការមេធាវីគ្មានព្រំដែន[16]

១៥- សារណាទាំងនេះត្រូវបានផ្សព្វផ្សាយក្នុងគេហទំព័ររបស់ អ.វ.ត.ក ហើយរាល់ព័ត៌មានដែលមានក្នុងសារណាទាំងនេះត្រូវបានអង្គបុរេជំនុំជម្រះយកមកពិចារណា។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថាក្នុងករណីមួយចំនួន ខ្លឹមសារសារណាទាំងនោះមានវិសាលភាពទូលំទូលាយជាងការដែលបានស្នើសុំជាក់ស្តែងទៅទៀត។ យ៉ាងណាក៏ដោយ សារណាទាំងនេះបានផ្តល់ជាជំនួយស្មារតីដល់អង្គបុរេជំនុំជម្រះ ទាក់ទងនឹងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមក្នុងសវនាការបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ទាក់ទងនឹងការថ្លឹងថ្លែងពីតុល្យភាពរវាងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសិទ្ធិរបស់ជនត្រូវចោទ ទាក់ទងនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ និងក្នុងយុត្តាធិការជាតិ ព្រមទាំងយុត្តិសាស្ត្រពាក់ព័ន្ធរបស់តុលាការក្នុងតំបន់។

## IV- សារណាតបរបស់ភាគី

*ក្តីស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត"* ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៨ នៃរឿងក្តីជនត្រូវចោទ នួន ជា (សំណុំរឿង: ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០១) C១១/៤០)។

[15] សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តីគឺ សមាគមអ្នកច្បាប់ដើម្បីការអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) "*សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តីស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន*" ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៨ នៃរឿងក្តីជនត្រូវចោទ នួន ជា (សំណុំរឿង: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ០១) C១១/៤១)។

[16] សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តីគឺ អង្គការ Redress Trust (Redress) អង្គការសហព័ន្ធសិទ្ធិមនុស្សអន្តរជាតិ (FIDH) អង្គការមេធាវីគ្មានព្រំដែន (ASF) "*សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី*" ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៨ នៃរឿងក្តីជនត្រូវចោទ នួន ជា (សំណុំរឿង: ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០១) C១១/៤២)។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C C.E.T.C

១៦- សហមេធាវីរបស់ជនត្រូវចោទទាំងបីរូបបានដាក់សារណារួមគ្នាមួយ ឆ្លើយតបទៅនឹងសារណារបស់ភាគីផ្សេងទៀត ក៏ដូចជាសារណារបស់អ្នកមិនមែនជាភាគីក្នុងរឿងក្តី ដែលក្នុងនោះ សហមេធាវីបានលើកឡើងនូវចំណុចបន្ថែមមួយចំនួនដូចខាងក្រោម:

(i) ភាគច្រើននៃសារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តីមិនអាចទទួលយកបានទេ ពីព្រោះសារណាទាំងនោះមិនបានឆ្លើយតប ឬទៅហួសពីបញ្ហាជាក់លាក់ដែលអង្គជំនុំជម្រះបានលើកឡើង ហើយសារណាទាំងនោះខុសទម្រង់នីតិវិធីច្បាប់។ សារណាភាគច្រើនផ្តោតតែទៅលើបញ្ហាហេតុផលទូទៅនៃការចូលរួមរបស់ដើមបណ្តឹងប្បវេណីជាជាងបញ្ហាផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

(ii) ជំហររបស់មេធាវីគួរត្រូវបានមើលឃើញថាជាការឆ្លុះបញ្ចាំងជាក់ស្តែង និងសមហេតុផលទៅលើច្បាប់ជាធរមានដែលមិនបានគិតទៅដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណាក់កាលមុនអង្គសេចក្តី ត្រូវតែជាក់លាក់តាមនីតិវិធី។

(iii) តាមវិធានផ្ទៃក្នុង ពុំមានការអនុញ្ញាតដូចដែលសហព្រះរាជអាជ្ញា និងអ្នកមិនមែនជាភាគីនៃរឿងក្តីលើកឡើងនោះទេ ហើយវិធាន ៧៤ ទទួលស្គាល់ភាពខុសគ្នារវាងភាគីអំពីសិទ្ធិរបស់ពួកគេ ក្នុងការធ្វើពាក្យបណ្តឹង ឬ ជំទាស់នឹងសេចក្តីសម្រេចមួយចំនួននៅចំពោះមុខអង្គបុរេជំនុំជម្រះដែលលើកជាសំណួរឡើងថាតើ សញ្ញាណនៃឋានៈជាភាគីពេញសិទ្ធិនោះមានន័យយ៉ាងដូចម្តេច។

(iv) អត្ថប្រយោជន៍សន្ទត់ជាមុនចំពោះការចូលរួមរបស់ជនរងគ្រោះ នឹងមិនថយចុះដោយសារការមិនអនុញ្ញាតអោយពួកគេចូលរួមក្នុងដំណើរការនីតិវិធី ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ននោះទេ។

(v) អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅតុលាការព្រហ្មទណ្ឌអន្តរជាតិបានទទួលស្គាល់ថា នីតិវិធីពាក់ព័ន្ធនឹងការដាក់ពាក្យដើម្បីសុំចូលរួម វាមានសារសំខាន់ក្នុងការការពារសិទ្ធិជនត្រូវចោទ។

(vi) ការអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងប្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្នអាចរំលោភលើគោលការណ៍សច្ចធារណ៍និរទោស និងគោលការណ៍សមភាពរវាងភាគីទាំង



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

(vii) យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបមានលក្ខណៈដោយឡែក ហើយមិនអាចយកមកអនុវត្តបានល្អចំពោះបញ្ហានៅទីនេះបានទេ។

(viii) ជំនួសមកវិញ ក្រុមមេធាវីការពារក្តីសូមស្នើអោយមានសេចក្តីណែនាំដែលត្រូវអនុវត្តដូចសេចក្តីណែនាំដែលស្នើឡើងដោយសហព្រះរាជអាជ្ញា។

១៧- សហព្រះរាជអាជ្ញាបានបញ្ជាក់ឡើងវិញនូវសេចក្តីសន្និដ្ឋានពីមុនរបស់ខ្លួន ហើយបានលើកទឡ្ហីករណ៍បច្ចុប្បន្នជាការឆ្លើយតបទៅនឹងការអះអាងរបស់សហមេធាវីដែលលើកឡើងថា នីតិវិធីរបស់សហចៅក្រមស៊ើបអង្កេតមិនត្រឹមត្រូវទេ ពីព្រោះចៅក្រមស៊ើបអង្កេតខ្លួនឯងមិនបានទទួលយកពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ[17]។ សហព្រះរាជអាជ្ញាលើកឡើងថា ទាំងវិធានផ្ទៃក្នុង ទាំងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ[18] ពុំបានតម្រូវឱ្យមានសេចក្តីសម្រេចដោយមានសំអាងហេតុណាមួយរបស់សហចៅក្រមស៊ើបអង្កេត នៅពេលទទួលយកពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះឡើយ ហើយលើកឡើងថា ការគ្មានយន្តការបែបនេះជាមូលហេតុសមហេតុសមផលដោយមូលហេតុគោលនយោបាយ។ ម្យ៉ាងវិញទៀត គេអះអាងថា អង្គបុរេជំនុំជម្រះមិនមានអំណាចទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី ឬសម្រេចថាពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចទទួលយកបាននោះទេ ពីព្រោះតាមវិធានផ្ទៃក្នុង មានតែនៅសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះប៉ុណ្ណោះដែលមានអំណាចនេះ ។

១៨- មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមានអាទិភាពជាងវិធានផ្ទៃក្នុង។ មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានយោងទៅមាត្រា ៥ នៃក្រមនេះ ដែលចែងថា ជនរងគ្រោះអាចចូលរួមក្នុង "បណ្តឹងអាជ្ញា" ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី

---

[17] សារណាតបរបស់សហព្រះរាជអាជ្ញាចំពោះសារណារួបរួមរបស់មេធាវីការពារក្តីស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៨ នៃរឿងក្តីជនត្រូវចោទ នួន ជា (សំណុំរឿង: ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០១) C១១/៤៩)។

[18] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី១) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៨ និង សេចក្តីណែនាំអនុវត្ត ០២/២០០៧ ស្តីពីការចូលរួមរបស់ជនរងគ្រោះ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ២០០៧។



PRE-TRIAL CHAMBER E.C.C.C * C.E.T.C CHAMBRE PRÉLIMINAIRE

00173244

C11/53



ដោយមិនត្រឹមតែដើរតួនាទីក្នុងបណ្ដឹងរដ្ឋប្បវេណីតែមួយមុខគត់ប៉ុណ្ណោះនោះទេ។ ក្រុមមេធាវីនេះរៀបរាប់បញ្ជាក់អំពីនីតិវិធីបើកសវនាការបណ្ដឹងឧទ្ធរណ៍នៅចំពោះមុខសភាស៊ើបសួររបស់កម្ពុជា និងលើកឡើងពីរឿងក្ដីដែលដើមបណ្ដឹងរដ្ឋប្បវេណីបានចូលរួមក្នុងរឿងបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្ដោះអាសន្ន។ ពួកគេលើកឡើងថា ការផ្អែកលើយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិជាការមិនត្រឹមត្រូវក្នុងរឿងនៅទីនេះទេ ដោយអះអាងថាក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមិនតម្រូវឱ្យជនរងគ្រោះបង្ហាញពីផលប្រយោជន៍ផ្ទាល់ខ្លួន ទាក់ទងទៅនឹងដំណាក់កាលនីតិវិធី ឬក្នុងពេលសវនាការខុសៗគ្នានោះទេ ប៉ុន្តែផ្ទុយទៅវិញ ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមក្នុងនីតិវិធីយ៉ាងពេញលេញ។ ពួកគេបានបន្តលើកឡើងបន្ថែមទៀតថា ការខកខានមិនបានដាក់សារណាជាលាយលក្ខណ៍អក្សរមិនមែនជាការរារាំងដល់ការធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ឡើយ។ លើសពីនេះទៅទៀតសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនឹងត្រូវប៉ះពាល់ ប្រសិនបើអង្គបុរេជំនុំជម្រះបដិសេធសិទ្ធិធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់របស់គេដែលពុំមានសេចក្ដីសន្និដ្ឋានពាក់ព័ន្ធណាមួយត្រូវធ្វើ ដូចដែលសហព្រះរាជអាជ្ញាបានស្នើឡើង។

## V- ច្បាប់ជាធរមាន

១៩- ប្រយោគទី១ នៃមាត្រា ៣៣ (ថ្មី) នៃច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក[19] ចែងថា:

*អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថា ដំណើរការកាត់សេចក្ដីប្រព្រឹត្តទៅប្រកបដោយយុត្តិធម៌ និងឆាប់រហ័សតាមនីតិវិធីដែលមានស្រាប់ជាធរមាន ដោយគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងការពារយ៉ាងត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី។*

២០- ប្រយោគទី២ នៃមាត្រា ៣៣ (ថ្មី) ដែលឆ្លុះបញ្ចាំងផងដែរក្នុងមាត្រា ២០ (ថ្មី) ស្ដីពីសហព្រះរាជអាជ្ញា

[19] មាត្រា៣៣ (ថ្មី) នៃច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ២០០១ ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦)។

00173245

C11/53



និងមាត្រា ២៣ (ថ្មី) ស្តីពីការស៊ើបអង្កេត ព្រមទាំងមាត្រា ១២ (១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក[20] បន្តថែងថា:

*ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសណាមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹង ភាពស្របគ្នានៃនីតិវិធីទាំងនេះជាមួយនឹងបទដ្ឋានអន្តរជាតិ គេអាចស្វះស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។*

**ក- វិធានផ្ទៃក្នុង**

២១- វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុងចែងក្នុងផ្នែកពាក់ព័ន្ធថា:

*ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវប្រកបដោយយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាឱ្យបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងអស់[21]។*

២២- វិធាន ២៣ ស្តីពីបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយជនរងគ្រោះ ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា:

*១- គោលបំណងនៃបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញគឺដើម្បី:*

*ក- ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់ និង*

*ខ- អនុញ្ញាតឱ្យជនរងគ្រោះអាចស្វែងរកសំណងផ្លូវចិត្ត និងសំណងសមូហភាព ដូចមានចែងក្នុងវិធាននេះ។*

---

[20] មាត្រា១២(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្តីពីការកាត់សេចក្តីក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានចុះហត្ថលេខាក្នុងឆ្នាំ ២០០៣។

[21] វិធាន២១(១)(ក) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី១) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ ២០០៨។



E.C.C.C * C.E.T.C TRIAL CHAMBER CHAMBRE PRELIMINAIRE

[....]

៣- នៅពេលណាក៏ដោយ ក្នុងអំឡុងពេលស៊ើបសួរ ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សររបស់ខ្លួនទៅសហចៅក្រមស៊ើបអង្កេតដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

។

អនុលោមទៅតាមបទប្បញ្ញត្តិស្តីពីការការពារជនរងគ្រោះ ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងនេះទៅសហព្រះរាជអាជ្ញា និងជនត្រូវចោទ។ សហចៅក្រមស៊ើបអង្កេតអាចសម្រេចចេញដីកាដោយមានសំអាងហេតុបដិសេធពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន។ ដីកានេះត្រូវបើកផ្លូវប្តឹងឧទ្ធរណ៍ដល់ជនរងគ្រោះ។

៤- ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅអង្គជំនុំជម្រះសាលាដំបូងរហូតដល់ពេលបើកសវនាការ។ ពាក្យបណ្តឹងនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរប្រគល់ឱ្យក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង និងត្រូវដាក់ចូលក្នុងកំណត់ហេតុនៃដំណើរការនីតិវិធី។ជនរងគ្រោះដែលបានដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលស៊ើបសួរ មិនតម្រូវឱ្យដាក់ពាក្យជាថ្មីម្តងទៀតនៅចំពោះមុខអង្គជំនុំជម្រះឡើយ។

[...]

៦- ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានអានុភាពដូចខាងក្រោម:

ក- នៅពេលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះក្លាយជាភាគីក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ។ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចត្រូវបានសាកសួរដូចសាក្សីធម្មតាចំពោះរឿងដដែលបានទេ និងអនុលោមទៅតាម វិធាន ៦២ ស្តីពីដីកាចាត់ឱ្យស៊ើបសួរជំនួស ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានសាកសួរក្នុងលក្ខខណ្ឌដូចគ្នាជាមួយនឹងជនត្រូវចោទ ឬជនជាប់ចោទ។

ខ- អង្គជំនុំជម្រះមិនត្រូវចេញសេចក្តីសម្រេច ចំពោះបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលផ្ទុយគ្នាទៅនឹងសេចក្តីសម្រេចផ្នែកបណ្តឹងអាជ្ញាចំពោះករណីរឿងតែមួយឡើយ។

គ- សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះអាចចាត់វិធានការពារ ដើមបណ្តឹងរដ្ឋប្បវេណី ដូចមានចែងក្នុងវិធាន ២៩។

៧- ជនរងគ្រោះដែលចូលរួមក្នុងនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងនាមជាដើមបណ្តឹង



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

រដ្ឋប្បវេណី មានសិទ្ធិត្រូវបានតំណាងដោយមេធាវីជាតិ ឬអន្តរជាតិ ដោយសហការជាមួយមេធាវីជាតិ។

*[...]*

៨- ដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុមអាចជ្រើសរើសមេធាវីឱ្យធ្វើជាតំណាងក្រុមជារួមចេញពីបញ្ជីដែលរៀបចំឡើងដោយអង្គភាពជនរងគ្រោះ។ លើសពីនេះទៅទៀត សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចរៀបចំឱ្យមានតំណាងរួមដូចខាងក្រោម:

ក- សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាចស្នើទៅក្រុមដើមបណ្តឹងរដ្ឋប្បវេណីឱ្យជ្រើសរើសមេធាវីម្នាក់ ឬច្រើននាក់ធ្វើជាតំណាងរួមក្នុងរយៈពេលកំណត់មួយ។

ខ- នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុម មិនអាចជ្រើសរើសមេធាវីធ្វើជាតំណាងឱ្យក្រុមបានតាមពេលវេលាកំណត់ដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើទៅអង្គភាពជនរងគ្រោះ ឱ្យធ្វើការជ្រើសរើសមេធាវីសម្រាប់តំណាងឱ្យក្រុមពួកគេ។ ក្នុងករណីនេះ អង្គភាពនេះត្រូវធ្វើការពិចារណាទៅលើបំណងប្រាថ្នារបស់ដើមបណ្តឹងរដ្ឋប្បវេណី និងស្ថានភាពពិសេសនៃសំណុំរឿង និងទំនាស់ផលប្រយោជន៍នៅក្នុងក្រុម ក៏ដូចជាការតម្រូវឱ្យគោរពប្រពៃណីក្នុងតំបន់ និងការជួយទៅដល់ក្រុមដែលងាយនឹងរងគ្រោះ។

គ- នៅពេលផលប្រយោជន៍យុត្តិធម៌តម្រូវ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចចាត់តាំងមេធាវីតំណាងឱ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់ពីពិគ្រោះយោបល់ជាមួយអង្គភាពជនរងគ្រោះ។

ឃ- សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ និងអង្គភាពជនរងគ្រោះត្រូវចាត់វិធានការសមស្របទាំងឡាយដើម្បីធានាថា ក្នុងការជ្រើសរើសមេធាវីរួមគ្នា ផលប្រយោជន៍ខុសគ្នាៗរបស់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗត្រូវបានគោរព និងទំនាស់ផលប្រយោជន៍ដទៃទៀតក៏ត្រូវបានជៀសវាង។

ង- គ្រប់ពេលវេលាទាំងអស់ តាមពាក្យបណ្តឹងដោយមានសំអាងហេតុ ដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំទៅសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ឱ្យពិចារណាឡើងវិញ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00173248

C11/53



*ពីការជ្រើសរើសមេធាវីរូមដោយអង្គភាពជនរងគ្រោះ ឬពីការចាត់តាំងរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ។ និង*

ច- *ដើមបណ្តឹងរដ្ឋប្បវេណី ដែលខ្វះលទ្ធភាពបង់ប្រាក់កម្រៃអោយមេធាវីរួម ដែលចាត់តាំងដោយសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចស្វែងរកជំនួយពីអង្គភាពជនរងគ្រោះ។*

*[...]*

២៣- វិធាន ៦៣(១)(ក) ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ចែងថា:

*សហចៅក្រមស៊ើបអង្កេត អាចសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ក្រោយពេលមានសវនាការតទល់គ្នា។ប្រសិនបើជនត្រូវចោទមិនទាន់មានជំនួយពីមេធាវីណាមួយនៅឡើយទេ សហចៅក្រមស៊ើបអង្កេតត្រូវប្រាប់ជនត្រូវចោទអំពីសិទ្ធិមានមេធាវីការពារ ដូចមានចែងក្នុងវិធាន ២១(១)(ឃ)។ ជនត្រូវចោទមានសិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន។ ក្នុងពេលសវនាការតទល់គ្នានេះ សហចៅក្រមស៊ើបអង្កេតត្រូវស្តាប់សហព្រះរាជអាជ្ញា ជនត្រូវចោទ និងមេធាវីជនត្រូវចោទ។ នៅពេលបញ្ចប់សវនាការតទល់គ្នា សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទត្រូវបានដោះលែងឲ្យមានសេរីភាព។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតសម្រេចឃុំខ្លួនបណ្តោះអាសន្ន សហចៅក្រមស៊ើបអង្កេតត្រូវចេញបង្គាប់ឲ្យឃុំខ្លួន។*

២៤- វិធាន ៧៤(៤) ទាក់ទងនឹងមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះចែងថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ដូចខាងក្រោម:

ក- ការបដិសេធពាក្យសុំឲ្យមានកិច្ចស៊ើបសួរណាមួយដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង។

ខ- ការមិនទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

គ- ការបដិសេធពាក្យសុំឲ្យប្រគល់មកវិញនូវវត្ថុដែលចាប់យក។



E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00173249



ឃ- ការបដិសេធពាក្យសុំរបាយការណ៍របស់អ្នកជំនាញ ដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង។

ង- ការបដិសេធពាក្យសុំធ្វើកិច្ចស៊ើបសួរបន្ថែមណាមួយដោយអ្នកជំនាញ ដែលអនុញ្ញាតក្រោមវិធាននេះ។

ច- ដីកាលើកលែងចោទប្រកាន់ ក្នុងករណីដែលសហព្រះរាជអាជ្ញាធ្វើបណ្តឹងឧទ្ធរណ៍។

ឆ- ការបដិសេធពាក្យសុំឲ្យប្តឹងទៅអង្គជំនុំជម្រះដើម្បីមោឃភាពកិច្ចស៊ើបសួរណាមួយ ឬ

ជ- ជាប់ទាក់ទងនឹងវិធានការការពារ។

២៥- វិធាន ៧៧ ចែងអំពីនីតិវិធីសម្រាប់បណ្តឹងឧទ្ធរណ៍ និងពាក្យសុំទៅអង្គបុរេជំនុំជម្រះ ហើយចែងនៅក្នុងផ្នែកដែលពាក់ព័ន្ធថា:

*៣- ប្រធានអង្គជំនុំជម្រះត្រូវផ្ទៀងផ្ទាត់ថា សំណុំរឿងនោះមានភាពពេញលេញ និងកំណត់កាលបរិច្ឆេទសវនាការ។ ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេតភាគី និងមេធាវីរបស់ភាគីទាំងអស់។*

*៤- សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីអាចមើលសំណុំរឿងរហូតដល់ថ្ងៃសវនាការ។ សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីត្រូវដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួនទៅក្រឡាបញ្ជីរបស់អង្គជំនុំជម្រះ ដូចមានចែងក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។ ក្រឡាបញ្ជីត្រូវចុះកាលបរិច្ឆេទនៃការទទួលឯកសារ និងដាក់ឯកសារទាំងនោះចូលទៅក្នុងសំណុំរឿងភ្លាម។*

*១០- ប្រធានអង្គជំនុំជម្រះ ត្រូវចាត់តាំងចៅក្រមជាតិមួយរូប និងចៅក្រមអន្តរជាតិមួយរូបអោយធ្វើជាសហចៅក្រមរបាយការណ៍។ សហចៅក្រមរបាយការណ៍ត្រូវរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរ ដែលត្រូវបង្ហាញអង្គហេតុដែលមានបញ្ហា និងសេចក្តីលម្អិតអំពីសេចក្តីសម្រេចដែលត្រូវប្តឹងឧទ្ធរណ៍ ហើយរបាយការណ៍នេះត្រូវដាក់ចូលទៅក្នុងសំណុំរឿង។ បន្ទាប់ពីសហចៅក្រមរបាយការណ៍បានអានរបាយការណ៍ សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីអាចធ្វើសេចក្តីសន្និដ្ឋានរបស់*



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

*ខ្លួនដោយសង្ខេប។ អង្គជំនុំជម្រះអាចបង្គាប់ឱ្យបុគ្គលទាំងឡាយចូលរួមដោយផ្ទាល់ ក៏ដូចជាការផ្ដល់នូវភស្តុតាង។*

*១៤- សេចក្ដីសម្រេចទាំងអស់ស្ថិតក្នុងវិធាននេះ រួមទាំងគំនិតជំទាស់ផងត្រូវមានសំអាងហេតុ និងចុះហត្ថលេខាដោយចៅក្រមទាំងនោះ។ សេចក្ដីសម្រេចនេះ ត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងភាគី ដទៃទៀតដោយក្រឡាបញ្ជីរបស់អង្គជំនុំជម្រះ។ សហចៅក្រមស៊ើបអង្កេត ត្រូវបន្តនីតិវិធីជាបន្ទាន់ ស្របតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។*

២៦- សន្ទានុក្រមនៃវិធានផ្ទៃក្នុងផ្ដល់និយមន័យលើពាក្យ "ដើមបណ្ដឹងរដ្ឋប្បវេណី" ថាជា "ជនរងគ្រោះដែលដាក់ពាក្យប្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះសាលាដំបូងដោយយោងទៅលើវិធានផ្ទៃក្នុងនេះ។ ពាក្យថា"ភាគី" គឺរួមបញ្ចូលទាំងសហព្រះរាជអាជ្ញា ជនត្រូវចោទ/ជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។

**ខ- នីតិវិធី និងទម្លាប់អនុវត្តនៅប្រទេសកម្ពុជា**

២៧- មាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា កំណត់ពីគោលបំណងរបស់បណ្ដឹងអាជ្ញា និងបណ្ដឹងរដ្ឋប្បវេណី:

*បណ្ដឹងអាជ្ញា និងបណ្ដឹងរដ្ឋប្បវេណីគឺជាបណ្ដឹងពីរផ្សេងគ្នា។*
*បណ្ដឹងអាជ្ញា មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្ដន្ទាទោសជននេះតាមច្បាប់កំណត់។*
*បណ្ដឹងរដ្ឋប្បវេណី មានគោលបំណងដើម្បីធ្វើអោយបានជួសជុលការខូចខាតដែលបណ្ដាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល[22]។*

[22] ការបកប្រែក្រៅផ្លូវការជាភាសាអង់គ្លេសថា: "*បណ្ដឹងអាជ្ញាមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្ដន្ទាទោសជននេះតាមច្បាប់កំណត់។ បណ្ដឹងរដ្ឋប្បវេណីមានគោលបំណងដើម្បីបានជួសជុលការខូចខាត...*
សាលដីកាអំពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

២៨- មាត្រា ៥ ចែងអំពីនីតិវិធីដែលជនរងគ្រោះអាចដាក់ពាក្យបណ្ដឹង និងចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណីដោយដាក់ពាក្យប្ដឹងទៅចៅក្រមស៊ើបសួរ។

២៩- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា រំពឹងឲ្យមានការចូលរួមរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងអំឡុងពេលស៊ើបសួរ។ មាត្រា ១៣៤ ចែងអំពីការស្នើសុំដែលភាគីដើមបណ្ដឹងរដ្ឋប្បវេណីអាចសុំទៅចៅក្រមស៊ើបសួរ។ មាត្រា ១៣៧ និង មាត្រា ១៣៨ ចែងថា កាលណាការស៊ើបសួរត្រូវបានបើក ជនរងគ្រោះអាចដាក់ជាសំណើ ឬពាក្យប្ដឹងទៅចៅក្រមស៊ើបសួរ ដើម្បីសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្ដោះអាសន្ន មាត្រា ២០៣ ដល់មាត្រា ២១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មិនបានចង្អុលទៅរកភាគីដើមបណ្ដឹងរដ្ឋប្បវេណីទេ ហើយ មាត្រា ២៦៨ ដែលចែងអំពីដីការបស់ចៅក្រមស៊ើបសួរ ដែលអាចត្រូវបានភាគីដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងឧទ្ធរណ៍បាន មិនបានរាប់បញ្ចូលដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ននោះទេ។ ប៉ុន្តែ មាត្រា ២៥៨ ដែលចែងពីសភាស៊ើបសួរ (ដែលមានមុខងារប្រហាក់ប្រហែលគ្នានឹងមុខងាររបស់អង្គបុរេជំនុំជម្រះ នៃអ.វ.ត.កដែរនោះ) ចែងថា បន្ទាប់ពីបានទទួលបណ្ដឹងឧទ្ធរណ៍ ប្រធានសភាស៊ើបសួរត្រូវជូនដំណឹងដល់គូភាគី និងមេធាវីរបស់ពួកគេអំពីកាលបរិច្ឆេទនៃការបើកសវនាការ។ ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី ឬមេធាវី ត្រូវចុះហត្ថលេខាដើម្បីបញ្ជាក់ថាបានទទួលការជូនដំណឹងនេះ ប្រសិនបើគេធ្វើឡើងដោយផ្ទាល់មាត់។ អនុលោមតាមមាត្រា ២៥៩ មេធាវីអាចពិនិត្យមើលសំណុំរឿងរហូតដល់ពេលបើកសវនាការ ហើយគូភាគី និងមេធាវីអាចប្រគល់សារណាដល់ក្រឡាបញ្ជី។ មាត្រា ២៦០ ចែងថា គូភាគីអាចត្រូវបង្គាប់ឲ្យចូលមកបង្ហាញខ្លួនក្នុងសវនាការ។

**គ- បទដ្ឋានអន្តរជាតិ**

**សេចក្ដីប្រកាសអំពីជនរងគ្រោះរបស់អង្គការសហប្រជាជាតិ**

---

*ដែលបណ្ដាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តធ្ងន់ធ្ងរនឹងព្យសនកម្មដែលខ្លួនបានទទួល"។*



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

៣០- នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តជាឯកច្ឆន្ទលើសេចក្ដីប្រកាសអំពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនិងការប្រើអំណាចដោយបំពាន ("សេចក្ដីប្រកាសអំពីជនរងគ្រោះរបស់អង្គការសហប្រជាជាតិ")។ សេចក្ដីប្រកាសនេះធ្វើឡើងដើម្បីជួយរដ្ឋាភិបាល និងសហគមន៍អន្តរជាតិប្រយោជន៍ទទួលស្គាល់ និងគោរពសិទ្ធិរបស់ជនរងគ្រោះដោយមិនឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនសង្ស័យ ឬ ជនល្មើស។ គោលការណ៍ទី ៦ ចែងថា:

> *ការឆ្លើយតបនៃដំណើរការតុលាការ និងរដ្ឋបាលទៅនឹងសេចក្ដីត្រូវការចាំបាច់របស់ជនរងគ្រោះគួរតែជួយសម្របសម្រួលតាមរយៈ៖*
>
> *(ក) ការជូនដំណឹងដល់ជនរងគ្រោះអំពីតួនាទីរបស់ពួកគាត់អំពីវិសាលភាព ពេលវេលា និងដំណើរការនៃដំណើរការនីតិវិធី ព្រមទាំងលក្ខណៈនៃរឿងក្ដីរបស់ពួកគេ ជាពិសេសគឺនៅពេលណាដែលមានការពាក់ព័ន្ធនឹងបទឧក្រិដ្ឋធ្ងន់ធ្ងរ និងប្រសិនបើពួកគេបានស្នើសុំចង់បានព័ត៌មានទាំងនេះ។*
>
> *(ខ) ការអនុញ្ញាតឲ្យមានការបញ្ចេញយោបល់ និងក្ដីកង្វល់របស់ជនរងគ្រោះ ដែលត្រូវយកមកធ្វើបទបង្ហាញ និងពិចារណាក្នុងដំណាក់កាលសមស្របនៃដំណើរការនីតិវិធី នៅពេលមានការប៉ះពាល់ដល់ផលប្រយោជន៍បុគ្គល ដោយគ្មានការប៉ះពាល់ដល់ជនជាប់ចោទ និងដោយស៊ីសង្វាក់គ្នាទៅនឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាតិដែលពាក់ព័ន្ធ[23]។*

៣១- គោលការណ៍ទាំងឡាយដែលចែងនៅក្នុងសេចក្ដីប្រកាសស្ដីពីជនរងគ្រោះរបស់អង្គការសហប្រជាជាតិក៏មានចែងផងដែរនៅក្នុងគោលការណ៍ជាមូលដ្ឋាន និងសេចក្ដីណែនាំស្ដីពីសិទ្ធិទទួលសំណងរបស់ជនរងគ្រោះពីការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលមហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តនៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ

[23] *គោលការណ៍ទី ៦ នៃសេចក្ដីប្រកាសអំពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋានសម្រាប់ជនរងគ្រោះដោយសារអំពើឧក្រិដ្ឋ និងការបំពានអំណាច* ដែលត្រូវអនុម័តដោយសេចក្ដីសម្រេចលេខ ៤០/៣៤ របស់មហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

00173253

C11/53



២០០៥។[24] គោលការណ៍ទាំងនេះមានចែងពីកាតព្វកិច្ចដែលអនុញ្ញាតអោយអ្នកដែលអះអាងថា ខ្លួនជាជនរងគ្រោះពីការរំលោភបំពានច្បាប់សិទ្ធិមនុស្ស ឬច្បាប់មនុស្សធម៌អន្តរជាតិ ចូលរួមក្នុងដំណើរការស្វែងរកយុត្តិធម៌ដោយមានប្រសិទ្ធភាព និងភាពស្មើគ្នា។

## វចនាសម្ព័ន្ធនៃតុលាការអន្តរជាតិ ឬតុលាការដែលមានលក្ខណៈជាអន្តរជាតិផ្សេងទៀត

៣២- លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ បានចែងក្នុងមាត្រា៦៨ (៣)ថា:

*ក្នុងករណីដែលមានការប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ តុលាការត្រូវអនុញ្ញាតអោយជនរងគ្រោះបញ្ចេញទស្សនៈ និងការព្រួយបារម្ភរបស់ខ្លួន ហើយត្រូវពិចារណាបញ្ហានេះនៅក្នុងដំណាក់កាលនានាក្នុងដំណើរការនីតិវិធី ដែលតុលាការសម្រេចថាមានភាពសមស្រប ហើយតុលាការត្រូវពិចារណាក្នុងឥរិយាបទមួយដែលមិនប៉ះពាល់ ឬផ្ទុយនឹងសិទ្ធិរបស់ជនជាប់ចោទ និងការជំនុំជម្រះដោយយុត្តិធម៌ និងមិនលំអៀងឡើយ*[25]។

៣៣- មាត្រា ១២.៣ នៃបទប្បញ្ញត្តិរបស់ UNTAET លេខ ២០០០/៣០ ក្នុងវិធាននៃនីតិវិធីព្រហ្មទណ្ឌអន្តរកាលរបស់ប្រទេសទីម័រខាងកើត ចែងថា:

*ជនរងគ្រោះគ្រប់រូបមានសិទ្ធិចូលរួមក្នុងសវនាការបណ្តឹងសុំអោយពិនិត្យសើរើឡើងវិញនៅចំពោះមុខចៅក្រមស៊ើបអង្កេត និងចូលរួមនៅគ្រប់សវនាការទាំងឡាយដែលពាក់ព័ន្ធនឹងបណ្តឹងសុំឱ្យមានការដោះលែងដោយមានល័ក្ខខ័ណ្ឌ អនុលោមទៅតាមផ្នែកទី៤៣ នៃបទប្បញ្ញត្តិនេះ។ ក្នុងការអនុវត្តសិទ្ធិនេះ ជនរងគ្រោះអាចមានតំណាងផ្នែកច្បាប់មកធ្វើជាតំណាងឱ្យខ្លួននៅក្នុងតុលាការ។ ដោយអនុលោមតាម ផ្នែកទី ៤៤ នៃបទប្បញ្ញត្តិនេះ ជនរងគ្រោះម្នាក់ៗមានសិទ្ធិទទួលបានការជូនដំណឹងជាមុនពីព្រះរាជអាជ្ញា ឬនគរបាល ក្នុងដំណើរការនីតិវិធី អំពីពេលវេលា និងទីកន្លែងនៃសវនាការបណ្តឹង*

---

[24] សេចក្តីសម្រេចមហាសន្និបាតរបស់អង្គការសហប្រជាជាតិលេខ ៦០/១៤៧។

[25] មាត្រា៦៨ (៣) នៃ*លក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ A/CONF.183/9* ចុះ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * PRÉLIMINAIRE

00173254

C11/53



*សុំអោយពិនិត្យសើរើឡើងវិញ ដូចមានយោងក្នុងផ្នែកទី២០ ទី២៩.៥ និងទី៤៣ នៃបទប្បញ្ញត្តិនេះ ប្រសិនបើជនរងគ្រោះនោះបានបញ្ជាក់ច្បាស់ជាមុនអំពីបំណងចង់ទទួលបានដំណឹងនេះដោយសម ស្របទៅកាន់តុលាការ ព្រះរាជអាជ្ញា ឬមន្ត្រីស៊ើបអង្កេត។*

៣៤- ក្រមនីតិវិធីព្រហ្មទណ្ឌបណ្ដោះអាសន្នរបស់កូសូវ៉ូ ចែងក្នុងមាត្រា៨០ មាត្រា៨១ និងមាត្រា៨២ ថា:

***មាត្រា ៨០***

*(១) ភាគីរងគ្រោះមានសិទ្ធិដាក់ពាក្យប្ដឹងទាមទារទ្រព្យសម្បត្តិ ក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ដោយអនុលោមតាមមាត្រា ១០៨ កថាខ័ណ្ឌទី ១ នៃក្រមនេះ*

*(២) នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីព្រហ្មទណ្ឌ ភាគីរងគ្រោះមានសិទ្ធិសុំឲ្យគេពិនិត្យមើលអង្គហេតុ និងមានសិទ្ធិស្នើសុំដាក់បង្ហាញភស្តុតាងដែលមានបន្ទុកដើម្បីរកឲ្យឃើញនូវបទល្មើសព្រហ្មទណ្ឌនោះ ស្វែងរកចារីនៃបទល្មើសព្រហ្មទណ្ឌនោះ ឬដើម្បីទាមទារទ្រព្យសម្បត្តិពីការប្ដឹងរបស់ខ្លួនបាន*

*(៣) ក្នុងការជំនុំជម្រះក្ដីពិតប្រាកដ ភាគីរងគ្រោះមានសិទ្ធិស្នើសុំបង្ហាញភស្តុតាង មានសិទ្ធិសួរចុងចោទ សាក្សី និងសាក្សីជំនាញ មានសិទ្ធិបញ្ចេញមតិយោបល់ និងបកស្រាយបញ្ជាក់អំពីសក្ខីកម្មរបស់ខ្លួន ព្រមទាំងមានសិទ្ធិផ្ដល់សេចក្ដីសន្និដ្ឋានផ្សេងៗទៀត និងដាក់ពាក្យប្ដឹង*

*(៤) អនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ ភាគីរងគ្រោះមានសិទ្ធិពិនិត្យមើលកំណត់ហេតុ និងឯកសារ ព្រមទាំងវត្ថុទាំងឡាយណាដែលយកមកធ្វើជាភស្តុតាង*

*(៥) រដ្ឋអាជ្ញាសាធារណៈ ចៅក្រមជំនុំជម្រះមុនអង្គសេចក្ដី និងចៅក្រមជំនុំជម្រះ ត្រូវជូនដំណឹងដល់ភាគីរងគ្រោះពីសិទ្ធិដូចដែលមានចែងក្នុងកថាខ័ណ្ឌទី ១ ដល់ទីកថាខ័ណ្ឌ ៤ នៃមាត្រានេះ។*

***មាត្រា ៨១***

*(១) ភាគីរងគ្រោះ និងតំណាងផ្នែកច្បាប់របស់ខ្លួនអាចអនុវត្តសិទ្ធិរបស់ខ្លួនបានផងដែរក្នុងដំណើរការនីតិវិធី តាមរយៈតំណាងស្របច្បាប់*

*(២) ភាគីរងគ្រោះ ឬតំណាងផ្នែកច្បាប់របស់ខ្លួន និងតំណាងស្របច្បាប់មានកាតព្វកិច្ចជូនដំណឹងដល់តុលាការរាល់ការផ្លាស់ប្ដូរអាសយដ្ឋាន ឬកន្លែងរស់នៅបច្ចុប្បន្ន*



E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00173255

C11/53



(៣) តំណាងស្របច្បាប់ត្រូវមានភារកិច្ចការពារសិទ្ធិរបស់ភាគីរងគ្រោះ ជាពិសេសការពារបូរណភាពរបស់ភាគីរងគ្រោះក្នុងអំឡុងពេលត្រួតពិនិត្យ មុនអាជ្ញាធរដែលបំពេញកិច្ចដំណើរការនីតិវិធី ហើយត្រូវមានភារកិច្ចដាក់ពាក្យប្តឹងនិងតាមដានការទាមទារទ្រព្យសម្បត្តិ

(៤) អនុលោមតាមមាត្រានេះ មេធាវីជនរងគ្រោះ នៃអង្គភាពការពារជនរងគ្រោះត្រូវជួយការពារសិទ្ធិរបស់ភាគីរងគ្រោះតាមការសមស្រប ក្នុងនាមជាតំណាងស្របច្បាប់របស់ភាគីរងគ្រោះ។

## មាត្រា ៨២

(១) ភាគីរងគ្រោះត្រូវមានតំណាងស្របច្បាប់ ចាប់តាំងពីពេលចាប់ផ្តើមដំបូងនៃដំណើរការរឿងក្តីព្រហ្មទណ្ឌ:

១) ប្រសិនបើភាគីរងគ្រោះ គឺជាកុមារ

២) ប្រសិនបើភាគីរងគ្រោះមានទំនាក់ទំនងគ្រួសារជាមួយចុងចោទ

៣) ប្រសិនបើដំណើរការនីតិវិធីធ្វើឡើងពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា ១៣៩ នៃក្រមព្រហ្មទណ្ឌបណ្តោះអាសន្ន ឬបទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងបូរណភាពផ្លូវភេទ ក្នុងជំពូកទី១៩ នៃក្រមព្រហ្មទណ្ឌបណ្តោះអាសន្ន លើកលែងតែបទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា ២០៣ នៃក្រមព្រហ្មទណ្ឌបណ្តោះអាសន្ននេះ

៤) ប្រសិនបើភាគីរងគ្រោះមានវិបត្តិ ឬពិការផ្នែកបញ្ញាស្មារតី

(៥) ប្រសិនបើតុលាការយល់ឃើញថា ភាគីរងគ្រោះងាយទទួលរងគ្រោះយ៉ាងពិសេស និងត្រូវការយ៉ាងចាំបាច់នូវជំនួយពីតំណាងស្របច្បាប់។

(២) ក្នុងករណីដូចដែលមានចែងក្នុងកថាខ័ណ្ឌទី ១ នៃមាត្រានេះ ប្រសិនបើភាគីរងគ្រោះ ឬតំណាងផ្នែកច្បាប់របស់ខ្លួនមិនបានរកតំណាងស្របច្បាប់ទេនោះ ប្រធានតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចដែលបំពេញកិច្ចដំណើរការនីតិវិធីក្នុងដំណាក់កាលមុនអង្គសេចក្តីនេះ ត្រូវតែចាត់តាំងតំណាងស្របច្បាប់អោយពួកគេដោយឯកឯង ដែលការចំណាយលើការចាត់តាំងនេះគឺជាបន្ទុករបស់រដ្ឋ។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

## VI- ការយល់ឃើញ

៣៥- បញ្ហាដែលកំពុងកើតឡើងនោះ គឺជាវិសាលភាពនៃវិធាន ២៣(១) ដែលចែងថា: "គោលបំណងនៃបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញគឺដើម្បី ក) ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ដោយគាំទ្រដល់ការចោទប្រកាន់"។ បញ្ហាដែលបានលើកឡើងនោះ គឺថាតើវិធាននេះមានបូកបញ្ចូលទាំងលទ្ធភាពរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមក្នុងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ក្នុងរឿងក្តីរបស់ជនដែលត្រូវចោទនេះដែរឬទេ។

៣៦- អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វិធាន ២៣(១)(ក) មានខ្លឹមសារច្បាស់លាស់ដែលថា ដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមនៅគ្រប់ដំណើរការនីតិវិធីព្រហ្មទណ្ឌទាំងអស់ រួមទាំងនីតិវិធីទាក់ទងបណ្តឹងឧទ្ធរណ៍ជំទាស់ការឃុំខ្លួនបណ្តោះអាសន្ននៅចំពោះមុខអង្គបុរជំនុំជម្រះ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថែមទៀតថា បទប្បញ្ញត្តិក្នុងវិធានផ្ទៃក្នុងដែលបានដកស្រង់មកបញ្ចូលក្នុងកថាខ័ណ្ឌទី ២០ ដល់កថាខ័ណ្ឌទី ២៦ បញ្ជាក់ច្បាស់ថា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមយ៉ាងសកម្មចាប់តាំងពីដំណាក់កាលស៊ើបអង្កេត។

៣៧- អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ការបញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងដំណើរការនីតិវិធី គឺជាការទទួលស្គាល់ការបន្តការបង្រួបបង្រួមជាតិ[26]។ អង្គបុរេជំនុំជម្រះពុំមានយុត្តាធិការក្នុងការពិនិត្យមើលវិធានផ្ទៃក្នុងឱ្យបានពេញលេញពាក់ព័ន្ធនឹងការចូលរួមរបស់ជនរងគ្រោះនោះទេ ផ្ទុយមកវិញអង្គបុរេជំនុំជម្រះមានយុត្តាធិការត្រឹមតែពិនិត្យមើលបញ្ហាដូចដែលបានលើកឡើងខាងលើតែប៉ុណ្ណោះ។

៣៨- យុត្តាធិការរបស់អង្គបុរេជំនុំជម្រះក្នុងវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ននេះ គឺឈរលើមូលដ្ឋានយុត្តាធិការរបស់សភាស៊ើបសួរ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះអាចស្វែងរកការណែនាំអំពីមុខងាររបស់ខ្លួន ដូចមានចែងនៅក្នុងមាត្រានៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះ

[26] សេចក្តីសម្រេចលេខ ៥៧/២២៨ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ និងបុព្វកថា នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

រាជាណាចក្រកម្ពុជាដែលចែងសម្រាប់សភាស៊ើបសួរ។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ២៥៩ និងមាត្រា ២៦០ មានចែងនូវបទប្បញ្ញត្តិសម្រាប់ភាគីដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងការចូលរួមក្នុងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាឃុំខ្លួន។ ពេលអានវិធាន ២៣(១) ដោយប្រៀបធៀបទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មានន័យថា ពាក្យពេចន៍ខ្លឹមសាររបស់វិធាននេះរំពឹងទុកឲ្យមានការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការនីតិវិធីនានារបស់ អ.វ.ត.ក រួមទាំងការចូលរួមក្នុងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នផងដែរ។

៣៩- យោងតាមមាត្រា១២ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មានកាតព្វកិច្ចមួយសម្រាប់អង្គបុរេជំនុំជម្រះដែលត្រូវពិនិត្យមើលថាតើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាមានភាពស្របគ្នានឹងបទដ្ឋានអន្តរជាតិ ទាក់ទងនឹងបញ្ហានេះដែរឬទេ ប្រសិនបើអង្គបុរេជំនុំជម្រះស្វែងរកការណែនាំពីក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៤០- នៅពេលពិចារណាពីការបញ្ចូលការចូលរួមនៅក្នុងដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាបង្គាប់អោយឃុំខ្លួន អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន ២៣ (១) នៃវិធានផ្ទៃក្នុងស្របទៅនឹងសេចក្តីណែនាំអន្តរជាតិស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ដូចមានចែងនៅក្នុងកថាខណ្ឌទី ៣០ និងកថាខណ្ឌទី ៣១ ខាងលើ[27]។ មិនត្រឹមតែប៉ុណ្ណោះ វិធាននេះស្របទៅនឹងនីតិវិធីរបស់តុលាការអន្តរជាតិ ដូចបានលើកឡើងនៅក្នុងកថាខណ្ឌទី ៣២ កថាខណ្ឌទី ៣៣ និងកថាខណ្ឌទី ៣៤។ នីតិវិធីខ្លះរបស់វិធានផ្ទៃក្នុង មានលក្ខណៈខុសគ្នាពីនីតិវិធីរបស់តុលាការផ្សេងទៀត ប៉ុន្តែ នីតិវិធីស្តីពីគោលការណ៍នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណាក់កាលឃុំខ្លួន ពុំមានលក្ខណៈខុសគ្នាឡើយ។ ម្យ៉ាងវិញទៀត ដោយពិចារណាលើការអនុវត្តរបស់អន្តរជាតិបែបនេះ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណាក់កាលឃុំខ្លួន ត្រូវចាត់ទុកជាការគោរព

[27] វិធានផ្ទៃក្នុង ២៣(១)។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅទំព័រទី៦២ និងទំព័របន្តបន្ទាប់ទៀត នៃ*របាយការណ៍ស្តីពីការចូល រួមរបស់ជនរងគ្រោះក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ* របស់ការិយាល័យស្រាវជ្រាវឧក្រិដ្ឋកម្មសង្គ្រាមនៅមហាវិទ្យាល័យនីតិសាស្ត្រ ក្រុងវ៉ាស៊ីនតោន ចុះនៅខែ វិច្ឆិកា ឆ្នាំ២០០៧ ប្រព័ន្ធដែលត្រូវបានអនុម័តយកមកប្រើទាក់ទងនឹងការចូលរួមរបស់ជនរងគ្រោះ មិនមែនថាវាគ្មានបញ្ហានោះទេ។

តាមជាទូទៅស្របតាមគោលការណ៍ជំនុំជម្រះដោយយុត្តិធម៌។ ជាទូទៅ គេទទួលស្គាល់បន្ថែមទៀតថា ដើមបណ្ដឹងរដ្ឋប្បវេណីអាចមានផលប្រយោជន៍នៅក្នុងសេចក្ដីសម្រេចពីបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាបង្គាប់អោយឃុំខ្លួនទៀតផង។

៤១- អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វិធានផ្ទៃក្នុងមានលក្ខណៈខុសពីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងបទប្បញ្ញត្តិដែលបានលើកឡើងខាងលើ ដោយសារតែវិធានផ្ទៃក្នុងពុំមានបទប្បញ្ញត្តិចែងអនុញ្ញាតឱ្យដើមបណ្ដឹងរដ្ឋប្បវេណីចូលរួមក្នុងសវនាការតទល់គ្នានៅចំពោះមុខសហចៅក្រមស៊ើបអង្កេតរបស់ អ.វ.ត.ក ឡើយ។ វិធាន ៦៣(១) នៃវិធានផ្ទៃក្នុងចែងថា សហចៅក្រមស៊ើបអង្កេតត្រូវស្ដាប់តែ“សហព្រះរាជអាជ្ញា ជនត្រូវចោទ និងមេធាវីជនត្រូវចោទប៉ុណ្ណោះ”[28]។ ក្នុងករណីសហព្រះរាជអាជ្ញាបើកការស៊ើបសួរដោយផ្អែកលើបណ្ដឹងដែលបានដាក់ជូន ពុំមាននីតិវិធីណាមួយតម្រូវឱ្យជូនដំណឹងដល់ម្ចាស់បណ្ដឹងថាតើ កិច្ចស៊ើបសួរត្រូវតែអនុវត្តតាមនីតិវិធីនេះឬយ៉ាងណានោះទេ។ តាមអានុភាពនៃវិធានផ្ទៃក្នុង ភាគីដែលនឹងក្លាយទៅជាដើមបណ្ដឹងរដ្ឋប្បវេណី ជាដំបូង ត្រូវដឹងអំពីការបើកកិច្ចស៊ើបសួរចំពោះជនត្រូវចោទណាមួយ នៅពេលទទួលបានសេចក្ដីជូនដំណឹងអំពីការចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នដូចមានចែងនៅក្នុងវិធាន៤៦ នៃវិធានផ្ទៃក្នុង។ ដូច្នេះ ដើមបណ្ដឹងរដ្ឋប្បវេណីអាចចូលរួមទៅបានតែក្នុងករណីដូចមានចែងក្នុងវិធាន ២៣(៣) នៃវិធានផ្ទៃក្នុង ចាប់ពីពេល និងបន្ទាប់ពីបើកកិច្ចស៊ើបសួរ និងបន្ទាប់ពីការចេញដីកា តាមវិធាន ៦៣ នៃវិធានផ្ទៃក្នុងជាធរមានប៉ុណ្ណោះ។ ក្នុងករណីដែលជនត្រូវចោទបានប្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ដូចមានចែងក្នុងវិធាន ៦៣(៤) នៃវិធានផ្ទៃក្នុង ដើមបណ្ដឹងរដ្ឋប្បវេណីនឹងមានសិទ្ធិ “ចូលរួមបាន” ដោយសារចាប់ពីពេលនេះទៅ បណ្ដឹងឧទ្ធរណ៍គឺជាផ្នែកមួយនៃ “នីតិវិធីរឿងក្ដីព្រហ្មទណ្ឌ” ដូចមានចែងក្នុងវិធាន ២៣(១) នៃវិធានផ្ទៃក្នុង។

៤២- ផលប៉ះពាល់នៃការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ននោះ គឺថាជនត្រូវចោទនឹងត្រូវប្រឈមនឹងបញ្ហា ដែលមិនបានលើកឡើងកាលពីពេលមុននៅក្នុងសវនាការតទល់គ្នា នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ ករណីនេះអាច

---

[28] វិធាន៦៣(១) វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី១) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៨ ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00173259

CMC83



បណ្ដាលឱ្យមានអតុល្យភាពនៅក្នុងដំណើរការនីតិវិធី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ប៉ុន្តែ ការអនុញ្ញាតអោយមានការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងនីតិវិធីដែលអ.វ.ត.ក បាន អនុម័ត ត្រូវតែអនុវត្តតាមលើករណីនេះ។

៤៣- វិធានផ្ទៃក្នុងចែងអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះប្រើប្រាស់មធ្យោបាយដើម្បីធានាថា រាល់ករណីមាន អតុល្យភាព ឬភាពអយុត្តិធម៌ជាក់ស្ដែងណាមួយកើតឡើង ក៏អាចលើកឡើងបានដែរ។ ជនត្រូវចោទ ត្រូវអនុញ្ញាតឱ្យឆ្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានដែលភាគីដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើង។វិធាន ៧៧(៤) នៃវិធានផ្ទៃក្នុងចែងថា ភាគីទាំងអស់ រួមទាំងដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវដាក់សារណា ជាលាយលក្ខណ៍អក្សរទៅក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ មុនពេលបើកសវនាការបណ្ដឹងឧទ្ធរណ៍។ ទោះក្នុងករណីណាក៏ដោយ អង្គបុរេជំនុំជម្រះអាចអនុញ្ញាតអោយជនត្រូវចោទ ឱ្យដាក់សេចក្ដី សន្និដ្ឋានតបជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ក្នុងករណីដែលមានការពាក់ព័ន្ធនឹងផល ប្រយោជន៍របស់ខ្លួន សូម្បីតែមានការលើកឡើងនូវបញ្ហាថ្មីនៅក្នុងពេលសវនការក៏ដោយ។ យើងអាច ទាញការសន្និដ្ឋានពីបទពិសោធន៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានថា ក្នុងការអនុវត្តមធ្យោបាយ បែបនេះ ផលប្រយោជន៍ជនត្រូវចោទអាចត្រូវបានការពារ ដោយមិនចាំបាច់មានការអនុម័តនីតិវិធី ខាងលើដែលអាចបណ្ដាលឱ្យកើតមាននូវបញ្ហាសំខាន់។[29] បន្ថែមលើករណីនេះ អង្គបុរេជំនុំជម្រះអាច ពិនិត្យមើលបទប្បញ្ញត្តិនៅក្នុងវិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង ដែលចែងថា:

*ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានភាពយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ*[30]។

៤៤- ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនត្រូវចោទ ត្រូវបានធានាយ៉ាងពេញលេញនៅក្នុងវិធានផ្ទៃក្នុង និងមានតុល្យភាពរវាងសិទ្ធិទទួលបានការចូលរួម តាមរយៈជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងដំណើរការនីតិវិធី នៅចំពោះមុខអង្គបុរេជំនុំជម្រះ ក្នុងរឿងបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាបង្គាប់អោយឃុំខ្លួន។

---

[29] សូមអាន *របាយការណ៍ស្ដីពីការចូលរួមរបស់ជនរងគ្រោះនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ* ខាងលើ។

[30] វិធាន២១(១)(ក) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី១) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ [illegible]



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

៤៥- ដូចមានបង្ហាញក្នុងកថាខ័ណ្ឌទី១ ដល់កថាខ័ណ្ឌទី២ នៃសេចក្តីសម្រេចនេះ នីតិវិធីរបស់អង្គបុរេជំនុំជម្រះត្រូវយកមកអនុវត្តតាម។ ប៉ុន្មានថ្ងៃមុនថ្ងៃសវនាការ មេធាវីត្រូវបានតែងតាំងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ហើយតក្រុមមេធាវីនេះបានបង្ហាញថា ពួកគេចង់ចូលរួមក្នុងសវនាការ។ អង្គបុរេជំនុំជម្រះបានធ្វើការបង្គាប់លើករណីនេះ ដោយសារវាមានភាពចាំបាច់ក្នុងការធានាដើម្បីកុំឱ្យមានការប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនត្រូវចោទ។

៤៦- នៅក្នុងករណីនេះ ជនត្រូវចោទនឹងប្រឈមនឹងករណីដែលថា ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ បន្ទាប់ពីសហមេធាវីបានធ្វើសេចក្តីសន្និដ្ឋានដំបូងរបស់ខ្លួននៅក្នុងសវនាការ។ មុនពេលសវនាការ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សារណាជាលាយលក្ខណ៍អក្សរទេ។ សហមេធាវីបានធ្វើការតវ៉ាលើការអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់។ អង្គបុរេជំនុំជម្រះបានស្នើឱ្យមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋាន ដែលខ្លួនបានលើកឡើងដោយផ្ទាល់មាត់ ទៅជាលាយលក្ខណ៍អក្សរ។ ខ្លឹមសារសេចក្តីសន្និដ្ឋានទាំងនោះ ត្រូវបានអង្គបុរេជំនុំជម្រះ និងភាគី យកមកធ្វើការពិចារណា នៅពេលលើកឡើងពីការអះអាងអំពីសិទ្ធិចូលរួមក្នុងសវនាការបណ្តឹងឧទ្ធរណ៍ជូនអង្គជំនុំជម្រះ។ អង្គបុរេជំនុំជម្រះបានធ្វើការសម្រេចបន្តសវនាការបណ្តឹងឧទ្ធរណ៍ដោយមានការចូលរួមពីដើមបណ្តឹងរដ្ឋប្បវេណី ដោយមានការឯកភាពពីភាគីទាំងអស់។ ខ្លឹមសារនៃសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី បានបង្ហាញអំពីការយល់ដឹងអំពីកាតព្វកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលគ្រាន់តែលើកនូវបញ្ហាដែលពាក់ព័ន្ធនឹងផលប្រយោជន៍របស់ខ្លួន នៅក្នុងរឿងក្តីដែលកំពុងដោះស្រាយប៉ុណ្ណោះ។ ប្រការនេះមិនបានបដិសេធលទ្ធភាពដែលថា នៅថ្ងៃខាងមុខ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានជម្រុញ និងតម្រូវឱ្យដាក់សារណារបស់ខ្លួនរួមគ្នា ក្នុងករណីដែលដើមបណ្តឹងរដ្ឋប្បវេណីមានការយល់ឃើញដូចគ្នាដើម្បីលើកកំពស់ប្រសិទ្ធភាពនៃដំណើរការនីតិវិធីនោះទេ។ សិទ្ធិរបស់ជនត្រូវចោទត្រូវបានគោរព ដោយសារជនត្រូវចោទត្រូវបានអនុញ្ញាតឱ្យដាក់សារណាជាលាយលក្ខណ៍អក្សរបន្ថែមទៀត ដើម្បីលើកឡើងពីលទ្ធភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមក្នុងសវនាការបណ្តឹងឧទ្ធរណ៍។ បន្ថែមពីនេះ ជនត្រូវចោទបានអនុវត្តសិទ្ធិដែលអង្គបុរេជំនុំជម្រះបានផ្តល់ជូន ដើម្បីឆ្លើយតបទៅនឹងសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងអំឡុងពេលធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ដំបូងរបស់ខ្លួន។ ដូច្នេះ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនត្រូវ



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00173261

C11/53



ចោទត្រូវបានថ្លឹងថ្លែង និងការពារ ដោយពុំមានការរំលោភបំពានណាមួយ ដូចដែលជនត្រូវចោទបានអះអាងនោះទេ។

៤៧- អង្គបុរេជំនុំជម្រះយល់ឃើញថា អនុលោមតាមវិធាន ២៣(៣) នៃវិធានផ្ទៃក្នុង វាជាសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការអនុញ្ញាតយល់ព្រមលើពាក្យសុំចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។វាពុំបានបង្ហាញលទ្ធភាពណាមួយដែលអនុញ្ញាតអោយជនត្រូវចោទប្ដឹងជំទាស់នឹងសេចក្ដីសម្រេចនេះឡើយ។ ដូច្នេះ អង្គបុរេជំនុំជម្រះមិនមានយុត្តាធិការសម្រេចថាតើ ការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេត ធ្វើឡើងស្របតាមវិធានផ្ទៃក្នុង ដូចដែលសហមេធាវីបានអះអាងនោះឡើយ។

៤៨- សហមេធាវីបានអះអាងថា ផលលំបាកនឹងអាចកើតឡើងនៅថ្ងៃខាងមុខ ប្រសិនបើចំនួនដើមបណ្ដឹងរដ្ឋប្បវេណីមានការកើនឡើង[31]។ អង្គបុរេជំនុំជម្រះបានពិនិត្យពិចារណាយ៉ាងល្អិតល្អន់អំពីផលប៉ះពាល់ពីសេចក្ដីសម្រេចរបស់ខ្លួននៅពេលខាងមុខ។ នៅក្នុងការអនុវត្តយុត្តាធិការរបស់ខ្លួន អង្គបុរេជំនុំជម្រះមិនអាចធ្វើការពិចារណាអំពីអង្គហេតុដែលអាច ឬមិនអាចកើតឡើងនៅថ្ងៃខាងមុខបានឡើយ ដោយសារតែយុត្តាធិការរបស់អង្គបុរេជំនុំជម្រះត្រូវបានកម្រិតត្រឹមតែអង្គហេតុដែលបានកើតឡើងហើយប៉ុណ្ណោះ មិនមែនអង្គហេតុដែលមិនអាចនឹងកើតឡើងនោះទេ។

៤៩- ដោយមានលក្ខណៈខុសពីលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ វិធានផ្ទៃក្នុងចែងថា នៅពេលទទួលបានការអនុញ្ញាត ដើមបណ្ដឹងរដ្ឋប្បវេណីអាចចូលរួមនៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី យោងតាមវិធាន២៣(៤) នៃវិធានផ្ទៃក្នុង។ យើងមិនចាំបាច់បង្ហាញអំពីផលប្រយោជន៍ពិសេសណាមួយ នៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធី ដូចដែលសហមេធាវីបានអះអាងនោះឡើយ។

---

[31] កថាខ័ណ្ឌទី ២៩ នៃសារណារួមគ្នា ស្ដីពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្ដោះអាសន្ន ចុះនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ នៃរឿងក្ដីជនត្រូវចោទ នួន ជា (សំណុំរឿង: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ០១) C១១/៤៥)។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00173262

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ:**

បដិសេធសំណើរបស់ជនត្រូវចោទ ដែលស្នើសុំ: (១) ដកសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី ចេញពីកំណត់ហេតុបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង (២) រារាំងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលក្រោយៗទៀត នៅក្នុងកិច្ចដំណើរការនីតិវិធីដែលពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន។

**សាលដីកានេះប្រកាសជាសាធារណៈ:**

ភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨

**អង្គបុរេជំនុំជម្រះ**

**ប្រធាន**

Rowan DOWNING ន័យ ថុល Katinka LAHUIS ហួត វុទ្ធី ប្រាក់ គឹមសាន

**ក្រឡាបញ្ជីសហការ**

កែវ [illegible] Dirk Jan LAMAN